# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 896

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : ការគ្រប់គ្រងព័ត៌មាននិងស្ថិតិកៅស៊ូធម្មជាតិតាមបច្ចេកវិទ្យាគមនាគមន៍ព័ត៌មាន (ICT: Information Communication Technology)

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/23

កាលបរិច្ឆេទបញ្ចប់គម្រោង 31/03/29

៣. ចំណាយគម្រោងសរុប $4,808,700

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT General Directorate of Rubber

អង្គភាពទទួលខុសត្រូវ អគ្គនាយកដ្ឋានកៅស៊ូ

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

១. គាំទ្រដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជានិងផែនការអភិវឌ្ឍវិស័យកសិកម្មកសិកម្មនិងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍កៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ 2011-2020

២.គម្រោងនេះចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទ

៣.គម្រោងនឹងពង្រឹងសមត្ថភាពដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើការគ្រប់គ្រង និងប្រើប្រាស់ព័ត៌មាន ស្ថិតិដំណាំកៅស៊ូដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឌីជីថល។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

[illegible]និងការលើកទឹកចិត្ត ការចុះបញ្ជីនិងការកាន់បញ្ជីគណនេយ្យ
និងការជំរុញការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម)

| | |
|---|---|
| កសិកម្ម និងការគ្រប់គ្រងដីធ្លី | Land Management |
| | Research and Extension Services |
| | Livestock |

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ពោធិ៍សាត់, បន្ទាយមានជ័យ, ឧត្តរមានជ័យ, ក្រចេះ, រតនគីរី, កំពង់ធំ, កោះកុង, កំពង់ចាម, ត្បូងឃ្មុំ , សៀមរាប, កណ្តាល, គ្រប់ខេត្តក្រុង, ស្វាយរៀង, កំពង់ស្ពឺ, ព្រៃវែង, បាត់ដំបង, ស្ទឹងត្រែង, ព្រះវិហារ, ព្រះសីហនុ, រាជធានីភ្នំពេញ, កំពត, ប៉ៃលិន, មណ្ឌលគីរី,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

លើកកម្ពស់ជីវភាពកសិករកៅស៊ូគ្រួសារ តាមរយៈការអភិវឌ្ឍកែលម្អយុទ្ធសាស្រ្តវិនិយោគ និងគោលនយោបាយ ដោយផ្អែកលើការធ្វើពិពិធកម្មកសិកម្ម និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពការងារ និងការគ្រប់គ្រងព័ត៌មានស្ថិតិកៅស៊ូធម្មជាតិ

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

- ការប្រមូលព័ត៌មានពីកសិករកៅស៊ូគ្រួសារ
- កាបង្កើតប្រព័ន្ធតាមដានការអនុវត្តរបស់កសិករកៅស៊ូគ្រួសារ
- ការចែករំលែកចំណេះដឹងដល់កសិករកៅស៊ូគ្រួសារផ្សេងទៀត និង
- ការគ្រប់គ្រង និងការទ្រទ្រង់គម្រោង។

(១) រៀបចំប្រព័ន្ធព័ត៌មាននិងស្ថិតិកៅស៊ូធម្មជាតិតាមបច្ចេកវិទ្យាគមនាគមន៍ព័ត៌មាន និងបំពាក់ ឧបករណ៍ (២) កសាងសមត្ថភាពមន្ត្រីក្នុងការប្រមូល គ្រប់គ្រង និងប្រើប្រាស់ទិន្នន័យកៅស៊ូ និង (៣) ការស្រង់ស្ថិតិកៅស៊ូធម្មជាតិ (៤) ការគ្រប់គ្រងនិងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធស្ថិតិកៅស៊ូធម្មជាតិ

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ចាប់ពីឆ្នាំ ១៩៥៧ រាជរដ្ឋាភិបាលបានផ្តួចផ្តើមធ្វើការអភិវឌ្ឍដាំដុះកៅស៊ូជាលក្ខណៈគ្រួសារនិងឯកជន នៅជុំវិញចម្ការកៅស៊ូកសិឧស្សាហកម្ម ដោយយកចម្ការកៅស៊ូកសិឧស្សាហកម្មជាស្នូល។ ការអភិវឌ្ឍន៍នៃការដាំដុះនេះត្រូវបានបញ្ចប់ទៅដោយសារសង្គ្រាមស៊ីវិលនៅចុងទសវត្សឆ្នាំ៦០។ ការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារត្រូវបានចាប់ផ្តើមឡើងវិញពីឆ្នាំ១៩៩០ ដោយគ្មានការគាំទ្រខាងផ្នែកបច្ចេកទេសនិងខាងផ្នែកហិរញ្ញវត្ថុនោះទេ។នៅក្នុងឆ្នាំ១៩៩៩ គម្រោងកៅស៊ូគ្រួសារ ដោយមានការជួយឧបត្ថម្ភហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍(AFD) ត្រូវបានបង្កើតឡើងនៅខេត្តកំពង់ចាមរយៈពេល១០ឆ្នាំ(១៩៩៩-២០០៨) ដោយបានធ្វើការដាំលើផ្ទៃដីចំនួន៤.០៤១ហិកតា ស្មើនឹង១.២៨៨គ្រួសារ ។ ចាប់ពីឆ្នាំ២០០៤មក កៅស៊ូគ្រួសារបានចាប់ផ្តើមដាំដុះកៅស៊ូ ដោយប្រើប្រាស់ធនធានរបស់ខ្លួនផ្ទាល់មានការរីកដុះដាលយ៉ាងខ្លាំងក្លា។ គិតត្រឹមឆ្នាំ២០១៨ ផ្ទៃដីដាំដុះដំណាំកៅស៊ូជាលក្ខណៈគ្រួសារសរុបមានចំនួន ១៦១.១០៣ ហិកតា ស្មើនឹង ៣៤.១៨៦ គ្រួសារ ដែលមានផ្ទៃដីចៀរជ័រចំនួន ១១៩.៨៣៧ហិកតា ស្មើនឹង ២៦.៦០០គ្រួសារ។ ដោយសារបច្ចេកទេសដំណាំកៅស៊ូមានភាពស្មុគស្មាញបានធ្វើឲ្យកសិករកៅស៊ូគ្រួសារ មានការយល់ដឹងអំពីបច្ចេកទេសដំណាំកៅស៊ូនៅមានកម្រិត ដូចជា៖(១) ចម្ការកៅស៊ូមិនសូវមានការថែទាំ បានល្អនិងមិនបានដាក់ជី (២)ការរៀបចំដីមិនបានត្រឹមត្រូវដែលបណ្តាលឲ្យមានការហូរច្រោះដី និង(៣)ការបើកមុខចៀរមិនបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសចៀរជ័រ។ ដូច្នេះ ដើម្បីជួយបង្កើនផលិតភាពចម្ការកៅស៊ូរបស់កសិករបានត្រឹមត្រូវបទដ្ឋានបច្ចេកទេស យើងត្រូវធ្វើការត្រួតពិនិត្យការអនុវត្តបច្ចេកទេសរបស់កសិករ និងបង្កើតប្រព័ន្ធតាមដាននិងចែករំលែកពីការអនុវត្តកសិកម្មល្អ(GAP) របស់កសិករគម្រូដល់កសិករកៅស៊ូគ្រួសារផ្សេងទៀត សំដៅជួយបង្កើនផលិតភាពចម្ការ និងបង្កើនប្រាក់ចំណូលខ្ពស់។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកដែលទទួលផលពីគម្រោងនេះគឺកសិករកៅស៊ូគ្រួសារ តាមខេត្តគោលដៅទាំង ២០ខេត្ត។ លើសពីនេះ ទៀត មន្ត្រីការិយាល័យកៅស៊ូនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២០ នឹងចូលរួមនៅក្នុងគម្រោងនេះ។ គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់កសិករកៅស៊ូគ្រួសារទាំងអស់ដើម្បីយល់អំពីការអនុវត្តពីបច្ចេកទេសដំណាំកៅស៊ូ ពីគ្នាទៅវិញទៅមក។ ទិន្នន័យស្ថិតិកៅស៊ូគឺជាធាតុចូលយ៉ាងសំខាន់ សម្រាប់ធ្វើការវិភាគពីស្ថានភាពកៅស៊ូនៅកម្ពុជានាពេលបច្ចុប្បន្ននិងក៏ដូចជាការព្យាករពីនិន្នាការទៅថ្ងៃអនាគត ដើម្បីអាចរៀបចំផែនការ និងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កៅស៊ូធម្មជាតិបានត្រឹមត្រូវនិងអាចអនុវត្តបាន។ បច្ចុប្បន្ន ស្ថិតិកៅស៊ូធម្មជាតិ គឺធ្វើឡើងដោយទទួលជា Hard Copy or Soft Copy ដោយប្រើប្រាស់កម្មវិធី Microsoft Excel និងត្រូវបានផ្ញើទៅវិញទៅមកតាមរយៈអ៊ីមែល (Email) ឬប្រព័ន្ធបណ្តាញសង្គមតេឡេក្រាម (Telegram) និងមិនមានភាពពេញលេញ ព្រមទាំងត្រូវចំណាយពេលវេលាច្រើនក្នុងការបញ្ចូលទិន្នន័យដែលងាយនឹងមានកំហុសឆ្គង មិនមានការប្រមូលផ្តុំនិងការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយ។ ភាព ខ្វះខាតទាំងនេះចាំបាច់ត្រូវកែលម្អផ្នែកស្ថិតិ ឱ្យប្រសើរជាងមុនដោយចាំបាច់ត្រូវមានប្រព័ន្ធព័ត៌មានជឿនលឿនថ្មីមួយ។ ហេតុដូចនេះទាមទារត្រូវមានគម្រោង "ការគ្រប់គ្រងព័ត៌មាននិងស្ថិតិកៅស៊ូធម្មជាតិដោយ ICT (Information Communication Technology)" នេះឡើង។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **គ្មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទាន់ចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌នាសង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**ផលប៉ះពាល់បរិស្ថាន៖**

**ចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ GHG តាមរយៈការស្រូបយកកាបូនឌីអុកស៊ីត(CO2)ពីបរិយាកាស និងជាគម្របព្រៃឈើ**

**ជួយកាត់បន្ថយការថយចុះនៃជីវជាតិដី និងការខូចនៃគុណភាពដី**

**ផលប៉ះពាល់សង្គម៖**

**- ជួយបង្កើតការងារនៅតាមជនបទ កាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ**

**- គម្រោងនឹងលើកកម្ពស់សុវត្ថិភាពស្បៀង(នៅដំណាក់កាលកៅស៊ូពេញវ័យផ្តល់ផល)**

**ដោយធ្វើឱ្យកសិករទទួលបានប្រាក់ចំណូលថេរជាប្រចាំមានរយៈពេលវែង(យ៉ាងតិច២៥ឆ្នាំ)**

**- ជួយឱ្យគ្រួសារកសិករដាំកៅស៊ូមានលទ្ធភាពដាំដុះដំណាំជូរតាមចន្លោះរង នៅពេលកៅស៊ូមិនទាន់ឲ្យផល។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **៣. ការកាត់បន្ថយហានិភ័យ** | 50 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការកាត់បន្ថយ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរស និងស្ត្រីក្នុងទីតាំងរបស់គ្រោងនេះទេ**
**បន្ថែមពីនេះគម្រោងមានការចូលរួមពីសកម្មភាពស្ត្រីចំនួន៥០%។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**អគ្គនាយកដ្ឋានកៅស៊ូមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងនេះ**
**ពីព្រោះអគ្គនាយកដ្ឋានកៅស៊ូធ្លាប់បានអនុវត្តគម្រោងជាច្រើនកន្លងមក។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

**គ្មាន**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្ដល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្ដានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**កំពុងស្វែងរកម្ចាស់ជំនួយ។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2022 | | 2023 | 2024 | 2025 | 2026 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2024-2026 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 13.2 | 188.5 | 70.5 | 272.2 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 10.2 | 14.2 | 14.2 | 38.6 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 25.6 | 20.6 | 46.2 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 3.0 | 148.7 | 35.7 | 187.4 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 168.1 | 417.2 | 402.2 | 987.5 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 62.5 | 16.5 | 0.0 | 79.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 52.1 | 0.0 | 0.0 | 52.1 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 53.5 | 400.7 | 402.2 | 856.4 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 181.3 | 605.7 | 472.7 | 1,259.7 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2022 | | 2023 | 2024 | 2025 | 2026 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2024-2026 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 181.3 | 605.7 | 472.7 | 1,259.7 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: